# របាយការណ៍លទ្ធផលការងារឆ្នាំ ២០២២
# និងលើកទិសដៅការងារឆ្នាំ ២០២៣ របស់មន្ទីរអភិវឌ្ឍន៍ជនបទ
# ខេត្តក្រចេះ

## សេចក្តីផ្តើម

ក្រសួងអភិវឌ្ឍន៍ជនបទ បានខិតខំប្រឹងប្រែយ៉ាងខ្លាំងក្នុងការកែប្រែក្លាយថវិកាឲ្យទៅជាឧបករណ៍សម្រាប់បម្រើគោលនយោបាយរបស់ក្រសួង ក៏ដូចជាគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ជាផែនទីសម្រាប់ចង្អុលផ្លូវ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ សម្រាប់តាមដាន និងអនុវត្តគោលនយោបាយផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ ជាអង្គភាពទទួលបន្ទុកអនុវត្តគម្រោង និងសម្របសម្រួលសកម្មភាពរបស់ក្រសួងអភិវឌ្ឍន៍ជនបទនៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន និងជាសេនាធិការរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការអនុវត្តសកម្មភាពទាំងឡាយស្របទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ កំណត់ទិសដៅផែនការ និងសកម្មភាពនានាឲ្យស្របតាមសភាពការណ៍ និងតម្រូវការជាក់ស្តែងរបស់ខេត្ត សំដៅលើកកម្ពស់កំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឲ្យកាន់តែប្រសើរតាមរយៈការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច រក្សាបាននូវនិរន្តរភាពបរិស្ថាន មានសមធម៌យេនឌ័រ និងការចូលរួមប្រកបដោយនិរន្តរភាពក្នុងដំណើរការអភិវឌ្ឍន៍ សំដៅរួមចំណែកការកាត់បន្ថយភាពក្រីក្រនៅជនបទ។ ក្នុងឆ្នាំ២០២២នេះមន្ទីរ បានអនុវត្តផែនការកម្មវិធីដែលបាន ស្នើឡើងជាក់ស្តែងមន្ទីរអភិវឌ្ឍន៍ជននបទខេត្តក្រចេះ បានអនុវត្តចំគោលដៅដែលដាក់ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងន័យកំណែទម្រង់ការប្រើប្រាស់ថវិកាជាតិឲ្យបានត្រឹមត្រូវ សុក្រិត្យ និងចំគោលដៅក្នុងការឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

## I. **សមិទ្ធផលសម្រេចបាន**

### ១. ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ស្ថាប័ន ជាអាទិភាពទី១ ដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្លាំងជាងគេ។ ការរីកចំរើននៃបច្ចេកវិទ្យាឌីជីថលបានជួយសម្រួលការងារច្រើនលើគ្រប់វិស័យទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ពិសេសទាក់ទងនឹងការបង្កើនល្បឿនអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច។ ក្នុងឆ្នាំ២០២២នេះ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ មានមន្ត្រីរាជការសរុបចំនួន ២៧រូប ស្ត្រី០៤រូប ដឹកនាំដោយប្រធានមន្ទីរ០១រូប អនុប្រធានមន្ទីរ០៣រូប ប្រធានការិយាល័យ១០រូប អនុប្រធានការិយាល័យ១០រូប/ស្ត្រី០៣រូប និងមន្ត្រីជាប់កិច្ចសន្យា០១រូប។ ការងារគ្រប់គ្រងមន្ត្រីរាជការ និងចរន្តការងាររដ្ឋបាល និងកិច្ចការទូទៅ ដំណើរការទៅបានល្អ

ប្រសើរជាមួយនឹងការអនុវត្តបានយ៉ាងខ្ជាប់ខ្ជួន នូវការណែនាំ និងលិខិតបទដ្ឋាននានារបស់ក្រសួង ក៏ដូចជារដ្ឋបាលខេត្ត ក្នុងនោះការងារបើកប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗបានប្រព្រឹត្តិទៅទាន់ពេលវេលារួមជាមួយនឹងយន្តការតាមដានត្រួតពិនិត្យថវិកាកម្មវិធីរបស់ការិយាល័យជំនាញ ដែលបានធ្វើឲ្យមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ កាន់តែមានភាពល្អប្រសើរឡើងក្នុងការដឹកនាំ និងគ្រប់គ្រង។ សម្រាប់ការងារពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងឆ្នាំ២០២២នេះ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានបញ្ជូនមន្ត្រីចំនួន១៤នាក់/ស្ត្រី០០នាក់ ចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាចំនួន០៩វគ្គ ក្នុងនោះបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងខេត្តចំនួន០៧វគ្គ និងក្រៅខេត្តចំនួន ០២វគ្គ។

**២. ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

ដើម្បីជានាប្រសិទ្ធិភាព និងប្រសិទ្ធផលការងារនៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានបន្តស្ថាបនា និងជួសជុលផ្លូវជនបទ ព្រមទាំងកែលម្អផ្លូវជនបទឲ្យក្លាយទៅជាផ្លូវធន នឹងការបម្រែបម្រួលអាកាសធាតុ។ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទបានដើរតួនាទីយ៉ាងសំខាន់ក្នុងការតភ្ជាប់ទំនាក់ទំនងរវាងអ្នកផលិត និងឈ្មួញកណ្តាល ដែលជាកាតាលីករសំខាន់ក្នុងការជំរុញឲ្យមានកំណើនសេដ្ឋកិច្ចជាតិ ពិសេសនៅតំបន់ជនបទ។ ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ ក្នុងឆ្នាំ២០២២ នេះ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានទទួលលទ្ធផលដូចខាងក្រោម៖

- ចុះសិក្សាផ្លូវជួសជុល ចំនួន ០១ខ្សែ ប្រវែង២,៥០គ.ម និងជួសជុលស្ពានបេឡេត៍កម្រាលឈើ ចំនួន ០២កន្លែង ប្រវែង ៣០ម៉ែត្រ ស្ថិតនៅភូមិកំពង់ព្នៅ-ភូមិកោះច្បារ ឃុំកោះខ្ញែរ ស្រុកសំបូរ
- ចុះស្រង់ទិន្នន័យផ្លូវបានចំនួន ០៤ខ្សែ ប្រវែង ៣៦ ០០០ ម៉ែត្រ ស្ថិតនៅឃុំដំរីផុង ស្រុកឆ្លូង និងស្រុកព្រែកប្រសព្វ
- ចុះពិនិត្យ និងវាយតម្លៃផ្លូវខូចខាត ដើម្បីរៀបចំសំណើសុំគម្រោងអន្តរាគមន៍បន្ទាន់ ចំនួន១ កំណាត់ខ្សែផ្លូវ ប្រវែង ២ ៦០០ ម៉ែត្រ ស្ថិតនៅឃុំអូរគ្រៀង ស្រុកសំបូរ
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវកែលម្អកម្រាលកៅស៊ូ ២ជាន់ ចំនួន៣ខ្សែ ប្រវែងសរុប៣២.៥០គ.ម សាងសង់ដោយគម្រោងRRIP-III របស់ក្រសួងអភិវឌ្ឍន៍ជនបទ ស្ថិតនៅឃុំឆ្លូង ឃុំដំរីផុង ឃុំកំពង់ដំរី ស្រុកឆ្លូង
- ក្រុមការងារអន្តរក្រសួងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុចុះត្រួតពិនិត្យ និងវាយតម្លៃផ្លូវខូចខាត អន្តរាគមន៍បន្ទាន់ ផ្លូវចំនួន២ កំណាត់ប្រវែង ៣ ៥០០ម៉ែត្រ ស្ថិតនៅឃុំអូរគ្រៀង ស្រុកសំបូរ
- ផ្លូវថែទាំជាលក្ខណៈប្រចាំចំនួន ៧ខ្សែ ប្រវែង ១០១ ៣០០ម៉ែត្រ ស្ថិតនៅក្នុងឃុំវឌ្ឍនៈ ឃុំសំបូរ ឃុំកំពង់ចាម ស្រុកសំបូរ,ឃុំកន្ទួត ឃុំថ្មី ឃុំសំបុក ឃុំគោលាប់ ឃុំជារ ស្រុកចិត្របុរី,ឃុំដំរីផុង ស្រុកឆ្លូង និងឃុំព្រែកប្រសព្វ ឃុំសោប ស្រុកព្រែកប្រសព្វ
- ផ្លូវថែទាំជាលក្ខណៈខួប ភូមិព្រែកប្រសព្វ-ភូមិខ្សាត់ ចំនួន១ខ្សែ ប្រវែង ៩ ៣៥០ម៉ែត្រ និងសាងសង់លូមូល ចំនួន ១កន្លែង, លូប្រអប់ ចំនួន១កន្លែង ស្ថិតនៅក្នុងឃុំព្រែកប្រសព្វ ឃុំកំពង់គរ ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ
- ចុះដាំកូនឈើចំនួន ១០០០ដើម អបសងខាងផ្លូវនៅឃុំរស្មីមានជ័យ ស្រុកសំបូរ ខេត្ត ក្រចេះ

- ចុះរាប់ចរាចរណ៍យានយន្តចំនួន ០២ខ្សែ ប្រវែង១២០គ.ម នៅឃុំអូរគ្រៀង ស្រុកសំបូរ, ឃុំ កំពង់ដំរី ឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ
- សាងសង់ទូលសុវត្ថិភាព ចំនួន០១កន្លែង នៅឃុំសោប ស្រុកព្រែកប្រសព្វ។

**៣. ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

ដើម្បីធានាលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាពលរដ្ឋជនបទឲ្យបានល្អប្រសើរ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានតម្រង់ទិសដៅរបស់ខ្លួនដើម្បីសម្រេចឲ្យបាននូវទស្សនវិស័យនៃគោលនយោបាយដែលបានកំណត់ថា " **ឆ្នាំ២០២៥ ប្រជាពលរដ្ឋនៅជនបទគ្រប់រូបត្រូវមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព** "។ មន្ទីរបានផ្តោតយកចិត្តទុកដាក់លើវិធានការចំនួន០៣សំខាន់ៗ គឺការប្រើប្រាស់បង្គន់អនាម័យ ការលាងសម្អាតដៃនឹងសាប៊ូ និងការបរិភោគទឹកស្អាត។ លទ្ធផលសំខាន់ដែលសម្រេចបានរួមមាន៖

- សាងសង់អណ្តូងស្នប់បានចំនួន ១៧ កន្លែង ឃុំកន្ទួត ចំនួន២អណ្តូង ឃុំដារ ចំនួន៣អណ្តូង ឃុំថ្មី ចំនួន២អណ្តូង ឃុំគោលាប់ ចំនួន៣អណ្តូង ឃុំ២ធ្នូ ២អណ្តូង ឃុំក្បាលដំរី ៣អណ្តូង ឃុំព្រែកសាម៉ាន់ ១អណ្តូង ឃុំព្រែកប្រសព្វ ១អណ្តូង
- ត្រួតពិនិត្យបច្ចេកទេសសាងសង់អណ្តូងស្នប់អណ្តូងបាន១៧ ទីតាំខាងលើ
- ចូលរួមចែករំលែកបទពិសោធការងារទឹកស្អាត និងអនាម័យ នៅក្នុងមូលដ្ឋានសុខាភិបាល នៅមន្ទីរសុខាភិបាលខេត្តក្រចេះ
- ចូលរួមកិច្ចប្រជុំប្រចាំត្រីមាសទី២ របស់ក្រុមការងារបច្ចេកទេសថ្នាក់ស្រុក និងក្រុង ដើម្បីតាមដានបច្ចុប្បន្នភាពផែនការ និងដោះស្រាយបញ្ហាប្រឈមដែលមាននៅថ្នាក់ក្រុង-ស្រុក។
- ចូលរួមពិធីបញ្ចុះបឋមសីលាបើកការដ្ឋាន សាងសង់ប្រពន្ធ័ចែកចាយទឹកទុយោបែបសហគមន៍ នៅភូមិអំពិលទឹក ឃុំកំពង់ចាម ស្រុកសំបូរខេត្តក្រចេះ
- ចូលរួមកិច្ចប្រជុំលើកដំបូង របស់ក្រុមការងារបច្ចេកទេសទឹកស្អាត និងអនាម័យថ្នាក់ក្រុង នៅក្រុងក្រចេះ ស្រុកចិត្របុរី និងស្រុកសំបូរ
- ចូលរួមប្រជុំជ្រើសរើសគណៈកម្មការគ្រប់គ្រងស្ថានីយចែកចាយទឹកទុយោសហគមន៍ក្រោមជំនួយរបស់អង្គការ World Vision Cambodia នៅភូមិអំពិលទឹក ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ
- ចូលរួមប្រជុំតាមដាន និងគូសផែនទីភូមិដើម្បីវាយតម្លៃ តម្រូវការ និងការខ្វះខាតផ្នែកទឹកស្អាត និងអនាម័យរបស់ប្រជាពលរដ្ឋនៅឃុំកំពង់ចាម ឃុំសោប គាំទ្រដោយអង្គការ World Vision Cambodia
- ចុះសិក្សាពីស្ថានភាពអនាម័យភូមិ គូសផែនទីអនាម័យភូមិ ដោយមានការចូលរួមសរុប១៣ភូមិ
- សកម្មភាពអនុវត្តន៍ និងការសហការជាមួយ អង្គការយូនីសេហ្វ ចូលរួមប្រជុំការងារទឹកស្អាត និងអនាម័យ(DWG) ទាំង៦ក្រុង/ស្រុក
- ចុះតាមដាននិងត្រួតពិនិត្យការសាងសង់បង្គន់លូភ្លោះពីរដួរ និងបង្គន់លើផ្ទះ សរុបចំនួន៣៣១ ខ្នង និង ២៦ឃុំ/សង្កាត់

- ចុះផ្សព្វផ្សាយស្តីពីវិធានការការពារជម្ងឺកូវីត១៩ តាមរយៈការចាក់មេក្រូតាមឃុំទាំង៤៧ឃុំ/សង្កាត់ ក្នុងខេត្តក្រចេះ
- សកម្មភាពចែកសាប៊ូដុំ ដល់គ្រួសារក្រីក្រសម្រាប់លាងដៃការពារ ជម្ងឺកូវីត១៩ សរុប៥៧,៥៩១ដុំ និងចំនួន២២ឃុំ។

**៤. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ គឺជាបញ្ហាស្នូលដែលរាជរដ្ឋាភិបាលកំពុងតែខិតខំដោះស្រាយដើម្បីការរស់នៅប្រកបដោយសុខដុមរមនា។ ការបង្កើនល្បឿនផលិតកម្មសេដ្ឋកិច្ចជនបទ និងសហគ្រិនភាព គឺដើម្បីគាំទ្រដល់ប្រាក់ចំណូលតាមគ្រួសារនៅជនបទឲ្យមានជីវភាពប្រសើរឡើង។ ក្នុងឆ្នាំ២០២២នេះ ការិយាល័យជំនាញនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានធ្វើបច្ចុប្បន្នភាពក្រុមឥណទានបានចំនួន០៤ក្រុម ដែលមានសមាជិកសរុបចំនួន១៥៥នាក់ ស្ត្រី១១៧នាក់ នៅឃុំគោលដៅចំនួន៤ឃុំ គឺ ឃុំព្រែកប្រសព្វ កោះច្រែង បុសលាវ និងឃុំវឌ្ឍនៈ។

- សកម្មភាពចុះចែកពូជកូនឈើហូបផ្លែ (កូនមៀន) ក្នុងគម្រោងអភិវឌ្ឍន៍ភូមិចម្រុះចំនួន១២៥គ្រួសារ ចំនួនកូនមៀន ៦២៥ដើម នៅឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ។

**៥. សមិទ្ធិផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ**

**៥.១. គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍**

- កែលម្អផ្លូវជនបទ ក្រាលកៅស៊ូ២ជាន់ ក្រគរទៅគោលាប់ ចំនួន១ខ្សែ ប្រវែង ៥គម ស្ថិតនៅសង្កាត់ក្រគរ ក្រុងក្រចេះ និងឃុំគោលាប់ ស្រុកចិត្របុរី សម្រេចបាន១០០%
- កែលម្អផ្លូវជនបទ ក្រាលកៅស៊ូ២ជាន់ អូរឬស្សីទៅថ្មកាំង ចំនួន១ខ្សែ ប្រវែង ៨,៣០គម ស្ថិតនៅ សង្កាត់អូរឬស្សី ក្រុងក្រចេះ និងឃុំគោលាប់ ស្រុកចិត្របុរី សម្រេចបាន១០០%
- កែលម្អផ្លូវជនបទ ក្រាលកៅស៊ូ២ជាន់ សំបូរទៅកោះច្បារក្រោម ចំនួន១ខ្សែ ប្រវែង ១០គម ស្ថិតនៅឃុំសំបូរ ឃុំកោះខ្ញែរ ស្រុកសំបូរ សម្រេចបាន១០០%។

**៥.២.គម្រោងកែលម្អផ្លូវជនបទជំហានទី៣ (RRIP-III)**

- កែលម្អផ្លូវជនបទ ក្រាលកៅស៊ូ២ជាន់ ឆ្លូងទៅស្រែជាំធឹង ១ខ្សែ ប្រវែង ៦១,២០គម ស្ថិតនៅឃុំឆ្លូង ឃុំដំរីផុង ឃុំកំពង់ដំរី ស្រុកឆ្លូង សម្រេចបាន៨០%
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវកែលម្អក្រាលកៅស៊ូ ២ជាន់ ចំនួន៣ខ្សែ ប្រវែងសរុប៣២,៥០គ.ម សាងសង់ដោយគម្រោងRRIP-III របស់ក្រសួងអភិវឌ្ឍន៍ជនបទ ស្ថិតនៅឃុំឆ្លូង ឃុំដំរីផុង ឃុំកំពង់ដំរី ស្រុកឆ្លូង។

**៥.៣. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ (CFWRDLEP)**

- បានអនុវត្តគម្រោងសាងសង់ផ្លូវដីសបានប្រវែង **៥២៣ ៤៤៦**ម ឃុំគោលាប់ ឃុំចង្រ្កង់ ឃុំថ្មី ស្រុកចិត្របុរី ឃុំស្វាយជ្រះ ស្រុកស្នួល ឃុំកំពង់ដំរី ស្រុកឆ្លូង
- បានអនុវត្តគម្រោងសាងសង់ផ្លូវដីក្រហមបាន ប្រវែង **៤៦ ៥៤៦**ម នៅឃុំកំពង់ចាម ស្រុកសំបូរ ឃុំដំរីផុង ឃុំកំពង់ដំរី ស្រុកឆ្លូង ឃុំគោលាប់ ស្រុកចិត្របុរី

- សាងសង់បង្គន់អនាម័យតាមទីសាធារណៈបានចំនួន ១០បង្គន់ នៅឃុំព្រែកសាម៉ាន់ ឃុំកញ្ជរ ឃុំដំរីផុង ឃុំឆ្លូង ស្រុកឆ្លូង, ឃុំតាម៉ៅ ស្រុកព្រែកបប្រសព្វ, ឃុំគោលាប់ ស្រុកចិត្របុរី។

**៥.៤. កិច្ចសហការជាមួយអង្គការយូនីសេហ្វ (UNICEF)**

- ចែកសំភារៈការពារជំងឺកូវី១៩ រួមមាន សាប៊ូលាងសម្អាតដៃចំនួន ៩០ ០០០ដុំ ខិតប័ណ្ណផ្សព្វផ្សាយចំនួន ១ ០០០សន្លឹក នៅឃុំចំនួន៤៧ឃុំ/សង្កាត់ ទូទាំងខេត្តក្រចេះ
- ប្រជុំត្រីមាស ឆ្នាំ២០២២ ស្តីពីការសាងសង់បង្គន់កលូភ្លោះពីរជួរ និងបង្គន់លើផ្ទះក្នុងតំបន់បញ្ហា ប្រឈមចំនួន៤៧ឃុំ/សង្កាត់ ទូទាំងខេត្តក្រចេះ
- ចូលរួមប្រជុំប្រចាំត្រីមាសស្តីពីផែនការសុវត្ថិភាពទឹកធន់នឹងបម្រែបម្រួលអាកាសធាតុ ដល់ឃុំគោលដៅរបស់យូនីសេហ្វទាំង១២ ក្នុងនោះមាន ៨ឃុំក្នុងស្រុកចិត្របុរី ១ឃុំនៅក្នុងស្រុកឆ្លូង និង ៣ឃុំនៅក្នុងស្រុកសំបូរ។

**៥.៥. អង្គការ EMW**

- ចូលរួមបដិភាគសាងសង់បង្គន់ជូនគ្រួសារក្រីក្រ ចំនួន៣៥០បង្គន់ ស្រុកឆ្លូង ស្រុកសំបូរ។

**៥.៦. គម្រោងពិពិកម្មកសិកម្មកម្ពុជា**

- ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីសំណើរផែនការពិពិធកម្មកសិកម្ម នៅសហគមន៍អូរគគីរ ឃុំដារ ស្រុកចិត្របុរី ចំនួន៥លើក
- ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីសំណើរផែនការពិពិធកម្មកសិកម្ម នៅសហគមន៍កសិកម្មបៃតងចម្រុះ ឃុំសោប ស្រុកព្រែកប្រសព្វ ចំនួន៦លើក
- ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីសំណើរផែនការពិពិធកម្មកសិកម្ម នៅសហគមន៍ចង្ក្រង់មានសំណាង ឃុំចង្ក្រង់ ស្រុកចិត្របុរី ចំនួន០៧លើក។

ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីសំណើរផែនការពិពិធកម្មកសិកម្ម នៅសហគមន៍កសិកម្មតេជោសម្បទានចំបក់ ស្រុកស្រុកព្រែកប្រសព្វ មានចំនួន០៥លើក។

## II. បញ្ហាប្រឈម

ឆ្លងតាមរយៈការបំពេញការងារកន្លងមកក្នុងឆ្នាំ២០២២ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានជួបនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោមៈ

- ការគ្រប់គ្រងផ្លូវដែលបានសាងសង់រួចនៅជួបការលំបាក ដោយការប្រើប្រាស់រថយន្តដឹកជញ្ជូនលើសទម្ងន់ ដែលនាំឲ្យរងការខូចខាត
- ប្រជាពលរដ្ឋ និងគណៈកម្មការនៅមានទស្សនៈពឹងផ្អែកលើជំនួយ
- ប្រជាពលរដ្ឋពុំទាន់យល់ដឹង អំពីការថែទាំសុខភាព និងអនាម័យឲ្យបានទូលំទូលាយ
- ប្រជាជននៅតំបន់ជនបទមួយចំនួន នៅតែមានភាពកង្វះខាតទឹកស្អាតសម្រាប់ប្រើប្រាស់
- មានការស្នើសុំពីអាជ្ញាធរភូមិ ឃុំ ស្រុក ខេត្ត និងសហគមន៍ ក្នុងការជួសជុលផ្លូវ សាងសង់ផ្លូវ និងសំណង់សិល្បការផ្សេងៗ ជាពិសេសផ្លូវដែលរងការខូចខាតដោយសារទឹកជំនន់តែមន្ទីរមិនមានលទ្ធភាព ឆ្លើយតបឲ្យបានគ្រប់សំណើ និងទាន់ពេលវេលា

- ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការថែទាំសមិទ្ធផលដែលបានផ្តល់ជូននៅមានកម្រិត
- ផ្លូវជនបទមួយចំនួនធាប់ទទួលរងការខូចខាត ដោយសារទឹកជំនន់ទន្លេ ជំនន់ទឹកភ្លៀង និងមានការដឹកជញ្ជូនលើសទម្ងន់កំណត់
- ថវិកាសម្រាប់បម្រើការជួសជុល និងថែទាំផ្លូវនៅពុំទាន់បានឆ្លើយតបទៅនឹងតម្រូវការផែនការប្រចាំឆ្នាំនៅឡើយ។

## III. ទិសដៅការងារឆ្នាំ ២០២៣

### ១.ការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ

- ថែទាំខួប MRD ១ខ្សែប្រវែង ១៥ គ.ម នៅឃុំកំពង់ចាម ស្រុកសំបូរ
- បន្តកែលម្អផ្លូវជនបទ ក្រាលកៅស៊ូ២ជាន់ ឆ្លងទៅស្រែជាំធឹង ១ខ្សែ ប្រវែង ៦១,២០គម ស្ថិតនៅ ឃុំឆ្លូង ឃុំដំរីផុង ឃុំកំពង់ដំរី ស្រុកឆ្លូង
- ថែទាំប្រចាំ ចំនួន០៩ខ្សែ ប្រវែង ១២០ គ.ម នៅឃុំដំរីផុង ស្រុកឆ្លូង ឃុំព្រែកប្រសព្វ ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ឃុំវឌ្ឍនៈ ឃុំក្បាលដំរី ឃុំល្វេស ឃុំស្រែជិះ ស្រុកសំបូរ
- ជួសជុលផ្លូវ ចំនួន១ខ្សែ ប្រវែង២គ.ម និងសាងសង់ស្ពានចំនួន ៣កន្លែង ប្រវែង ៨៤ម៉ែត្រ នៅ ឃុំកោះខ្ញែរ ឃុំល្វេសមានជ័យ ស្រុកសំបូរ
- រាប់ចរាចរណ៍ ចំនួន០៣ខ្សែ ប្រវែង ៥០គ.ម នៅឃុំអូរគ្រៀង ឃុំកំពង់ចាម ស្រុកសំបូរ
- ដាំកូនឈើអមសងខាងផ្លូវ ចំនួន ១ ០០០ដើម នៅឃុំល្វេសមានជ័យ ឃុំក្បាលដំរី ស្រុកសំបូរ
- សាងសង់ទីទួលសុវត្ថិភាព ០១កន្លែង នៅឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ។

### ២.ការផ្តល់សេវាសុខភាព និងលក្ខខណ្ឌនៃការរស់នៅសម្រាប់សាធារណៈជន

- ចុះបំផុសការងារសហគមន៍ដឹកនាំអនុវត្តអនាម័យ (CLTS) នៅក្នុងស្រុកព្រែកប្រសព្វ ស្រុកចិត្របុរី ស្រុកឆ្លូង ស្រុកសំបូរ និងក្រុងក្រចេះ ខេត្តក្រចេះ
- ចុះផ្សព្វផ្សាយអប់រំសុខភាពអនាម័យ និងបំផុសអោយប្រជាពលរដ្ឋចូលរួម សាងសង់បង្គន់អនាម័យ ដោយខ្លួនឯងក្នុង ស្រុកឆ្លូង ស្រុកចិត្របុរី ស្រុកព្រែកប្រសព្វ ស្រុកសំបូរ និងក្រុងក្រចេះ
- ចុះតាមដាន និងជំរុញអោយប្រជាពលរដ្ឋស្មគ្រ័ចិត្តផ្លាស់ប្តូរទំលាប់ខ្លួនឯង ចុះផ្ទៀងផ្ទាត់ភូមិ (ODF) នៅក្រុងក្រចេះ ស្រុកឆ្លូង ព្រែកប្រសព្វ និងស្រុកសំបូរ
- រៀបចំផែនការភូមិបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល (ODF) នៅស្រុកចិត្របុរី ស្រុកឆ្លូង ស្រុកព្រែកប្រសព្វ ស្រុកសំបូរ និងស្រុកស្នួល
- សាងសង់បង្គន់ជូនគ្រួសារក្រីក្រចំនួន ១៥០បង្គន់ នៅស្រុកព្រែកប្រសព្វ ខេត្តក្រចេះ
- សាងសង់អណ្តូងស្នប់គ្រប់ប្រភេទ ចំនួន ២៦អណ្តូង នៅឃុំកោះច្រែង ឃុំថ្មី ឃុំកន្ទួត ឃុំដារ ស្រុកចិត្របុរី, ឃុំព្រែកប្រសព្វ ឃុំសោប ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ, ឃុំកំពង់ចាម ឃុំ ស្រែជិះ ឃុំក្បាលដំរី ឃុំវឌ្ឍនៈ ស្រុកសំបូរ
- សាងសង់ស្រះសហគមន៍ ចំនួន០១ នៅឃុំកំពង់ចាម ស្រុកសំបូរ
- សាងសង់ប្រព័ន្ធចែកចាយទឹកខ្នាតតូចចំនួន ២កន្លែង នៅឃុំបឹងចារ ឃុំថ្មី ស្រុកចិត្របុរី
- សហការណ៍ជាមួយបណ្តាអង្គការនានា។

### ៣.ការលើកកម្ពស់កម្រិតជីវភាពរស់នៅតាមជនបទ

- ចុះស្រង់ទិន្នន័យគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចនៅស្រុកព្រែកប្រសព្វ ស្រុកចិត្របុរី និងស្រុកសំបូរ

- ចុះស្រង់ទិន្នន័យជនជាតិដើមភាគតិច នៅក្នុងស្រុកស្ទួល ស្រុកសំបូរ និងស្រុកចិត្របុរី
- ប្រជុំផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច នៅស្រុកសំបូរ ស្រុកស្នួល និងស្រុកចិត្របុរី
- ប្រារព្ធពិធីទិវាជនជាតិដើមភាគតិចនៅស្រុកសំបូរ
- ចុះធ្វើបច្ចុប្បន្នភាពគណៈកម្មាអភិវឌ្ឍន៍ភូមិ(គ.អ.ភ) ស្រុកសំបូរ ស្រុកឆ្លូង ស្រុកចិត្របុរី ស្រុកស្នួល
- ចុះតាមដានគម្រោងអភិវឌ្ឍន៍ភូមិចម្រុះ (ចែកកូនឈើហូបផ្លែ) ស្រុកសំបូរ ខេត្តក្រចេះ។

**៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

- គាំទ្រ និងសម្របសម្រួលការងារហិរញ្ញវត្ថុ និងបៀវត្ស ចំនួន១២ខែ ក្នុងឆ្នាំ២០២៣
- គ្រប់គ្រងគម្រោងសមាហរណកម្មផែនការឃុំ/សង្កាត់ តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងរបស់ការិយាល័យជំនាញដែលប្រើប្រាស់ថវិកាកម្មវិធី ឆ្នាំ២០២៣។

ក្រៅពីនេះ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ នៅបន្តធ្វើការងារជាមួយស្ថាប័ន និងអង្គការដៃគូរអភិវឌ្ឍន៍នានាក្នុងខេត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅជនបទ។

**សេចក្តីសន្និដ្ឋាន**

តាមរយៈសមិទ្ធផលដែលសម្រេចបាន ក្នុងឆ្នាំ២០២២ នេះបានធ្វើឲ្យការអភិវឌ្ឍមូលដ្ឋានមានសន្ទុះប្រែប្រួលយ៉ាងឆាប់រហ័ស ទាំងផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ច ពិសេសជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែមានភាពប្រសើរឡើងជាលំដាប់។ ការងារផ្លូវលំជនបទ កាន់តែត្រូវបានពង្រីកទៅតាមតំបន់ដាច់ស្រយាលធ្វើឲ្យទីផ្សារ និងជនបទកាន់តែជិតគ្នាព្រមទាំងធ្វើឲ្យការងារ ទំនាក់ទំនងកាន់តែមានភាពងាយស្រួលឡើង។ ការងារផ្គត់ផ្គង់ទឹកជនបទ ពិតមែនតែនៅជួបការលំបាកក្នុងតំបន់ខ្លះ ប៉ុន្តែយើងបាននឹងកំពុងបន្តការសាងសង់អណ្តូង និងជីកស្រះបន្ថែមក្នុងតំបន់ទាំងនោះរួមទាំងការអប់រំផ្នែកអនាម័យឲ្យកាន់តែស៊ីជម្រៅ និងកាន់តែទូលំទូលាយទៅតាមតំបន់ជនបទ។ ការងារពង្រឹងភាពជាម្ចាស់ការរបស់មូលដ្ឋាន យើងបានយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលគណៈកម្មាធិការអភិវឌ្ឍន៍ភូមិឲ្យចេះរៀបចំ និងគ្រប់គ្រងផែនការអភិវឌ្ឍភូមិ និងធ្វើឲ្យសហគមន៍កាន់តែមានស្មារតីទទួលខុសត្រូវចេះការពារ និងថែទាំសមិទ្ធផលដែលមានក្នុងភូមិបានកាន់តែល្អជាងមុន។ សរុបសេចក្តីមក យើងឃើញថាការអនុវត្តគោនយោបាយ និងផែនការអភិវឌ្ឍន៍ជនបទ បានរួមចំណែកយ៉ាងល្អប្រសើរក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ និងគោលនយោបាយ ស្តីពីការផ្តល់សេវាសាធារណៈរបស់រដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តាមរយៈការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ធ្វើឲ្យប្រជារដ្ឋមានល័ក្ខខ័ណ្ឌល្អប្រសើរក្នុងជីវភាពរស់ប្រចាំថ្ងៃ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។